# ហេព្រើរ ជំពូកពីរ ១

…?…នៅទីនេះក្នុងថ្នាក់រៀន ហើយរីករាយជាមួយ…[កន្លែងទទេនៅលើកាសែត—អេដ។] ហើយឥឡូវនេះដំបូងនៃគម្ពីរហេព្រើរ គឺប៉ុល យើងបានរកឃើញថា ឬយើងជឿថា។ ទេវវិទូនៅទីបញ្ចប់ គេមិនដឹងថាមួយណា ឬអ្នកណាសរសេរវាទេ។ ប៉ុន្តែ ខ្ញុំជឿថា អ្នកដែលមានការយល់ដឹងខាងវិញ្ញាណនឹងឃើញវាគឺជាប៉ុល។ វាជា—វាត្រូវបានជឿ ដោយអ្នកនិពន្ធភាគច្រើនថាជាប៉ុល។ ហើយរបៀបយ៉ាងម៉េចដែលគាត់…

2 នៅក្នុងជំពូកទី១ យើងបានរកឃើញថាវាជាការលើកតម្កើងព្រះអម្ចាស់យេស៊ូវ។ អូ របៀបដែលគាត់បាននាំយក មកដើម្បីបង្ហាញដោយ—តាមរយៈបទពិសោធន៍ដែលគាត់មាននៅលើផ្លូវទៅក្រុងដាម៉ាស។ ឥឡូវនេះពីដំបូង ប៉ុលគឺជា ទេវវិទូពិតប្រាកដម្នាក់។ ប៉ុលត្រូវបានបង្រៀនក្រោមកាម៉ាលាលជាគ្រូដ៏ល្អម្នាក់នៅសម័យនោះ។ ហើយគាត់ជាមនុស្សឆ្លាតនិងវាងវៃ ហើយជាអ្នកប្រាជ្ញព្រះគម្ពីរដ៏ឆ្លាតម្នាក់។

3 ហើយខ្ញុំបានរកឃើញវា នៅពេលគាត់នៅតាមផ្លូវចុះទៅក្រុងដាម៉ាស ដោយមានចុតហ្មាយនៅក្នុងហោប៉ៅរបស់គាត់ ដើម្បីចាប់អស់អ្នកដែលនៅក្នុងផ្លូវនៃដំណឹងល្អចាស់ដែលមានពរ ហើយមនុស្សម្នាក់នេះស្មោះត្រង់ណាស់។ ប៉ុន្តែ ខ្ញុំតែងតែជឿថាតាំងពីប៉ុលបានឃើញស្ទេផានស្លាប់ ខ្ញុំគិតថាវាច្បាស់ជានៅក្បែរគាត់។ ពេលគាត់ព្រមឯកភាពឱ្យស្ទេផានទទួលមរណភាព ហើយកាន់អាវធំរបស់អ្នកដែលគប់ដុំថ្ម ពេលនោះប៉ុលមានទោសដោយសារឈាមរបស់ស្ទេផាន។ ហើយគាត់បានសារភាពហើយនិយាយថា "ខ្ញុំមិនសក្តិសម" បាននិយាយថា "ព្រោះខ្ញុំបានបង្ហូរឈាមរបស់ទ្រង់—ទុក្ករបុគ្គល ស្ទេផានរបស់ទ្រង់។" ដោយសារតែ គាត់បានធ្វើជាសាក្សី។

4 ហើយប្រសិនបើអ្នកធ្វើសាក្សីចំពោះអ្វីមួយ អ្នកមានទោសដូចជាអ្នកចូលរួមជាមួយវាដែរ។ ដូច្នេះប្រសិនបើយើងធ្វើជាសាក្សី ចូរនិយាយថា "អូ បាទ ពួកគេមិនគួរធ្វើបែបនេះទេ *ដូច្នេះហើយដូច្នេះ*" ចូរប្រយ័ត្ននូវអ្វីដែលអ្នកនិយាយ ព្រោះអ្នកមានទោសតាមរបៀបដែលការវិនិច្ឆ័យរបស់អ្នក។ បើមិនអាចសម្រេចចិត្ត កុំ

និយាយអ្វីចេញ ទុកឲ្យនៅតែវាទៅ។ បន្ទាប់មក នៅពេលដែលអ្នកថ្លែងទីបន្ទាល់ថាអ្នកជាគ្រិស្ទាន នោះអ្នកនឹងមានកំហុស។ ឃើញទេ? អ្នកមានកំហុសក្នុងការធ្វើជាគ្រិស្ទាន ហើយអ្នកត្រូវតែរស់នៅប្រឈមរឿងនោះ។ ហើយនៅពេលដែលព្រះជាម្ចាស់បង្កើត—ការសន្យានៅក្នុងព្រះគម្ពីរ…ខ្ញុំឃើញបុរសម្នាក់នៅទីនេះនៅលើកៅអីរុញ។ នៅពេលដែលព្រះជាម្ចាស់ធ្វើសេចក្ដីសន្យាមួយ ទ្រង់ទទួលខុសត្រូវចំពោះការសន្យានោះ លុះត្រាតែទ្រង់នាំវាឱ្យសម្រេច។ ទ្រង់ព្រះត្រូវទទួលខុសត្រូវពេលទ្រង់ធ្វើការសន្យា។ ហើយបទគម្ពីរទទួលខុសត្រូវរហូតដល់ពួកគេបានសម្រេច។ ឃើញទេ? ពួកគេគឺ—ពួកគេនៅទីនោះជា—ជាសេចក្ដីថ្លែងការណ៍ដែលព្រះបានធ្វើ។ ហើយវាត្រូវតែបំពេញឬព្រះជាម្ចាស់ទ្រង់មានទោស។ ឃើញទេ?

5 ដូច្នេះប៉ុល ដែលធ្វើជាគ្រូ ហើយមកតាមផ្លូវទៅក្រុងដាម៉ាសនៅថ្ងៃនោះប្រហែលជា យូរប្រហែលពេលថ្ងៃត្រង់ តាមខ្ញុំស្មាន។ មានពន្លឺដ៏អស្ចារ្យមួយបានភ្លឺចេញពីស្ថានសួគ៌ ហើយវាបានធ្វើឲ្យគាត់ងងឹតភ្នែក ហើយគាត់—គាត់បានធ្លាក់មកលើដី។ ហើយគាត់បាននិយាយថាគាត់ចង់ដឹងថាវាជានរណា។ លោកបានថ្លែងថា សំឡេងមួយបាននិយាយថា "សុល សុល ហេតុអ្វីបានជាអ្នកបៀតបៀនខ្ញុំ?" ខ្ញុំជឿលើគម្ពីរកិច្ចការជំពូកទី៨។

ហើយគាត់បាននិយាយថា "តើទូលបង្គំបានបៀតបៀនអ្នកណា?"

6 សំឡេងក៏ត្រឡប់មកវិញថា "ខ្ញុំជាព្រះយេស៊ូវ។" អូ! "ខ្ញុំគឺជាព្រះយេស៊ូវ ហើយវាជាការលំបាកសម្រាប់អ្នកក្នុងការទាត់នឹងជន្លួញ។" ហើយកាលនោះព្រះយេស៊ូវជាអ្វី? ព្រះយេស៊ូវទ្រង់ជាពន្លឺ គ្រាន់តែជាពន្លឺដ៏ធំដែលភ្លឺចាំង។

7 ឥឡូវនេះដើម្បីលើកទឹកចិត្តពួកយើងនិងទទួលបានគ្រឹះនៅទីនេះ។ តើទ្រង់ជាពន្លឺដោយរបៀបណា កាលទ្រង់ជាមនុស្ស? ឥឡូវនេះ គ្មាននរណាម្នាក់ទេ…

មានទាហានមួយក្រុមទៅជាមួយប៉ុល ជាអ្នកយាមព្រះវិហារចុះទៅចាប់ខ្លួន។ ប៉ុលជាប្រធានក្រុម។ ហើយពួកគេចុះទៅចាប់មនុស្សទាំងនោះ សម្រាប់យុទ្ធនាការរបស់ពួកគេជាដើម និងសម្រាប់ក្ដីសង្ឃឹមខាងសាសនារបស់ពួកគេដែលដាក់នៅក្នុងពួកគេ។

8 ប៉ុន្តែឥឡូវនេះ នៅទីនេះគឺព្រះយេស៊ូវជាពន្លឺដ៏ធំមួយ។ ឥឡូវនេះ ប្រសិនបើ
អ្នកចាំថា កាលពីដើមដំបូង ព្រះយេស៊ូវជាពន្លឺ។ ព្រះយេស៊ូវគឺជារូបសញ្ញាដែល
ចេញពីព្រះ។ ហើយទ្រង់គឺជា...ទ្រង់ជាទេវតានៃសេចក្ដីសញ្ញា ដែលបានដឹកនាំ
កូនចៅអ៊ីស្រាអែលឆ្លងកាត់ទីរហោស្ថាន។ ហើយទ្រង់គឺជាបង្គោលភ្លើង ដែល
ពួកគេបានមើល។ ហើយទ្រង់គឺជា...ហើយនៅពេលដែលទ្រង់គង់នៅលើផែនដី
ទ្រង់មានបន្ទូលថា "ខ្ញុំមកពីព្រះ ហើយខ្ញុំត្រឡប់ទៅឯព្រះវិញ។" ដូច្នេះ ប្រសិនបើ
ទ្រង់បានមកពីបង្គោលភ្លើង ចូលទៅក្នុងមនុស្ស នោះប្រសិនបើទ្រង់បានត្រលប់
ទៅកន្លែងដែលទ្រង់គង់ នោះទ្រង់បានត្រឡប់ទៅរកពន្លឺម្ដងទៀត។ ហើយនៅ
ទីនោះគឺជាពេលដែលប៉ូលបានឃើញទ្រង់ ទ្រង់គឺជាពន្លឺ។

9 ឥឡូវនេះ ទាហានទាំងអស់ដែលនៅជាមួយប៉ុលមិនបានឃើញពន្លឺទេ។
ដូច្នេះតើវាអាចទៅរួចទេដែលម្នាក់អាចមើលឃើញវា ហើយអ្នកផ្សេងទៀត
មិនឃើញវា? ពិតប្រាកដណាស់។ ត្រូវហើយ។ លោកប៉ុលបានឃើញវា ប៉ុន្តែ
ពួកគេផ្សេងទៀតមិនបានឃើញពន្លឺទេ។

10 ឥឡូវនេះ នៅពេលដែលពេត្រុសនៅក្នុងគុក យើងដឹងថាពន្លឺនេះបានចូល
មកក្នុងគុក ហើយបានបើកទ្វារ។ ហើយគាត់គឺជា...ពន្លឺនោះបានធ្វើឲ្យអ្នកយាម
ឯទៀតងងឹតភ្នែក ពេលដែលពួកគេដើរចេញ ពេត្រុសក៏ទៅ។ ហើយពេលទៅដល់
ទ្វារ ក៏បើកដោយខ្លួនវា ស្ងាត់ៗ ហើយបិទពីក្រោយគាត់។ ចេញពីគុកខាងក្នុង
គាត់បានទៅទ្វារខាងក្រៅ។ វាបើកដោយខ្លួនវាផ្ទាល់ បិទដោយស្ងៀមស្ងាត់។
ហើយបន្ទាប់មកគាត់បានទៅចន្លោះនោះ បានចេញទៅតាមផ្លូវទីក្រុង។ ហើយ
គាត់ត្រដុសភ្នែកដូចជាចង់និយាយថា "តើខ្ញុំសុបិនទេឬ?" គាត់មិនដឹងថាមានអ្វី
កើតឡើងទេ។ ប៉ុន្តែទេវតានៃព្រះអម្ចាស់ ជាទេវតាដដែលដែលជាបង្គោលភ្លើង
ដែលដើរ លោកម៉ូសេទៅកាន់សមុទ្រ ហើយនាំនាងចេញទៅ អូ ហើយសមុទ្រ
មរណៈ...សមុទ្រក្រហមបានឈរឡើងជាជញ្ជាំងទាំងសងខាង ហើយអ៊ីស្រាអែល
បានឆ្លងកាត់។

11 ហើយនៅពេលដែលពួកគេមកដល់ទន្លេយ័រដាន់ដែលជោទឹកនោះ ទ្រង់
មិនបានឱ្យឃើញទ្រង់ផ្ទាល់នៅទីនោះទេ។ ប៉ុន្តែទ្រង់គង់នៅទីនោះ ព្រោះទ្រង់
គ្រាន់តែបើកវាឡើង។ ហើយពួកគេបានឆ្លងកាត់នៅក្នុងខែមេសា នៅពេលដែល
វាលទំនាបពោរពេញដោយទឹក។ ហើយទ្រង់បាននៅរដូវផ្ការីក ហើយទ្រង់បានការ

ពារព្រិលមិនឲ្យរលាយឡើយ ព្រោះវាមិនមានជញ្ជាំងខ្ពស់ជាងនេះឡើយ។ វាគ្រាន់តែឈប់។ នោះជាព្រះយេហូវ៉ារបស់យើង។ នោះជាព្រះអម្ចាស់យេស៊ូវរបស់យើង។ គ្រាន់តែឈប់ ហើយពួកគេបានដើរឆ្លងកាត់លើដីស្ងួត។

12 ឥឡូវនេះ ព្រះបានសន្យាថាទ្រង់នឹងថែរក្សាពួកគេ ដូច្នេះទ្រង់មានកាតព្វកិច្ចចំពោះសេចក្ដីសន្យារបស់ទ្រង់។ ឥឡូវនេះ ប៉ុល បានដឹងអំពីរឿងទាំងនេះ ហើយបានដឹងរឿងទាំងនោះ គាត់មានឯកសិទ្ធិ ព្រោះព្រះកំពុងមានបន្ទូលផ្ទាល់ទៅប៉ុល។ ទ្រង់មិនបាននិយាយទៅកាន់ទាហានដែលនៅជាមួយគាត់ទេ។ គាត់គ្រាន់តែនិយាយទៅកាន់ប៉ុលប៉ុណ្ណោះ។

13 ឥឡូវនេះនៅពេលដែល—នៅពេលដែលទេវតារបស់ព្រះអម្ចាស់ចុះមកក្នុងទម្រង់ជាផ្កាយ ហើយអ្នកមើលផ្កាយ ដែលជាអ្នកប្រាជ្ញនៃប្រទេសឥណ្ឌា នៅពេលដែលពួកគេបានឃើញផ្កាយនោះ ហើយដើរតាមវារាប់រយម៉ាយ។ ហើយវាបានឆ្លងកាត់គ្រប់កន្លែងសង្កេត ពីព្រោះពួកគេបានរក្សាពេលវេលាដោយផ្កាយ។ ហើយគ្មាននរណាម្នាក់បានឃើញផ្កាយនោះ ក្រៅពីអ្នកប្រាជ្ញ។ អូ! វាមិនរំភើបទេឬ?

14 បន្ទាប់មក អ្នកឃើញទេ ព្រះមិនទាក់ទងនឹងអង្គការទេ។ ទ្រង់មិនដោះស្រាយជាមួយក្រុមមនុស្សទេ។ ទ្រង់ដោះស្រាយជាមួយបុគ្គល។ ទ្រង់បង្ហាញអង្គទ្រង់ដល់បុគ្គលម្នាក់ៗ។ ហើយឥឡូវនេះ—ឥឡូវនេះដើម្បីនិយាយនេះ មិនមែនថា...ព្រះស្គាល់ចិត្តខ្ញុំ។ ហើយមិននិយាយនេះសម្រាប់ខ្លួនឯង ជាការសរសើរផ្ទាល់ខ្លួន ឥឡូវនេះគ្រាន់តែដើម្បីនៅទីនោះ។ ប៉ុន្តែ តើអ្នកដឹងទេថា ព្រះតែមួយនោះ គឺព្រះយេស៊ូវតែមួយនោះ គង់នៅជាមួយយើងនៅព្រឹកនេះ? តើអ្នកដឹងទេថា អ្នករាល់គ្នាម្នាក់ៗមាន សាក្សីផ្ទាល់ខ្លួនខ្លះអំពីវានៅពេលនេះ ថាទ្រង់នៅទីនេះ? ហើយគឺជា...ទ្រង់បានធ្វើអ្វីមួយសម្រាប់យើងនៅក្នុងថ្ងៃនេះ ដែលទ្រង់មិនបានធ្វើនៅថ្ងៃផ្សេងទៀត ទ្រង់មានរូបភាពរបស់ទ្រង់ក្នុងថ្ងៃនេះ។ យើងបានព្យួរវានៅ*ទីនោះ*។ ឃើញទេ? បង្គោលភ្លើង គឺជាព្រះអម្ចាស់យេស៊ូវដដែល។

15 មើលពីរបៀបដែលទ្រង់ធ្វើការឥឡូវនេះ។ ប្រសិនបើទ្រង់ជាព្រះអម្ចាស់យេស៊ូវ ទ្រង់នឹងធ្វើដូចគ្នា ដ្បិតព្រះគម្ពីរបានចែងថា "ទ្រង់គឺនៅដដែលកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។"

16 ឥឡូវនេះ មុនពេលដែលប៉ុលនឹងប្រកាសអ្វី ទោះជានេះត្រូវ ឬខុសក៏ដោយ ដំបូងគាត់បានចុះទៅស្រុកអេស៊ីបហើយចំណាយពេលបីឆ្នាំ ដើម្បីដឹងថាវាជាគម្ពីរ

ឬអត់។ តើអ្នកធ្លាប់ដឹងទេ? ក្រោយពីប៉ុលបានប្រែចិត្ត គាត់បានទៅស្រុកអេស៊ីប អស់រយៈពេលបីឆ្នាំ។ នៅទីនោះគាត់បានស្នាក់នៅ ហើយនៅទីនោះគាត់បានរៀន ប្រាជ្ញាដ៏អស្ចារ្យនេះ។

17 ឥឡូវនេះ មិននៅក្នុងការប្រៀបធៀបណាមួយទេ ខ្ញុំគ្រាន់តែផ្តល់ឱ្យអ្នកនូវ
របៀបដែលព្រះវិញ្ញាណបរិសុទ្ធនៅតែដដែល។ ឥឡូវនេះ ក្រុមជំនុំរបស់ខ្ញុំនៅទីនេះ ចងចាំ កាលពីប៉ុន្មានឆ្នាំមុន នៅពេលដែលទេវតានេះនឹងបង្ហាញខ្លួនហើយនឹង បង្ហាញរឿង។ ខ្ញុំមានការសង្ស័យបន្តិចអំពីវា។ អ្នកទាំងអស់គ្នាដឹងហើយ អ្នកជា ចាស់ទុំ។ ប្រសិនបើអ្នក...បើត្រឹមត្រូវ លើកដៃឡើង នៅពេលអ្នកឮ។ បាទ។ សូម ក្រឡេកមើល ព្រះវិហារ កាលពីសម័យបុរាណ។ ឃើញទេ? ខ្ញុំមានការសង្ស័យ ព្រោះគ្រូអធិប្បាយប្រាប់ខ្ញុំថាវាមកពីអារក្ស។ ហើយខ្ញុំជឿវា ប៉ុន្តែខ្ញុំបានរង់ចាំ។ ខ្ញុំ នឹងមិននិយាយអ្វីអំពីវាទេ។

18 ប៉ុន្តែ សូមថ្វាយព្រះពរដល់ព្រះនាមនៃព្រះអម្ចាស់! នៅយប់មួយ ទ្រង់យាងចុះ
មក ជាទេវតា ហើយបើកសម្តែង ក្នុងគម្ពីរថា ទ្រង់គង់នៅ។ ហើយនៅពេលដែល ខ្ញុំបានឃើញវានៅក្នុងបទគម្ពីរ បន្ទាប់មកដើម្បីបំផ្ទុះជុំវិញពិភពលោកជាមួយនឹងវា នូវរាជ្យសារ។

19 ពីទីនោះបានចេញទៅជា អូរ៉ល រ៉ូបឺត អេ អេ អាឡែន តូមមី អូសបន តូមមី ហ៊ី
ក និងអ្វីៗជាច្រើនទៀត។ ឃើញទេ? វាជាសារទៅកាន់ប្រជាជន។

20 ហើយព្រះយេស៊ូវគឺដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ គឺតាម
បទគម្ពីរ ទ្រង់ក៏ដូចគ្នា។ ទ្រង់ធ្វើដូចគ្នា។ ទ្រង់គឺដូចគ្នា។ ហើយទ្រង់ធ្វើការដូចគ្នា។ ទ្រង់បង្ហាញអង្គទ្រង់ដូចគ្នា។ ហើយទ្រង់នៅទីនេះ ព្រឹកនេះដូចគ្នា។ ឥឡូវនេះយើង អាចឃើញទ្រង់ ក៏ប្រហែលជាមិនមែនទេ។ ទោះជាយ៉ាងណាក៏ដោយ យើងមាន សាក្សីម្នាក់ឥឡូវនេះថាទ្រង់នៅទីនេះ។

21 ឥឡូវនេះ យើងរកឃើញថា ប៉ុល តាមបទពិសោធន៍នេះ ហើយការសរសេរ
សំបុត្រទាំងនេះ ដែលភាគច្រើនចេញពីគុក គាត់បានប្រៀបធៀបគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មី។ សូមចាំថា អ្នកនិពន្ធចុងក្រោយនៃព្រះគម្ពីរនេះ ដោយការ បើកសម្តែង ព្រះបានយាងចុះមក ហើយបានប្រាប់គាត់ថា "ប្រសិនបើអ្នកណា បន្ថែមអ្វីទៅក្នុងវា ឬយករបស់ណាមួយចេញពីវា ដូចគ្នានេះចំណែករបស់គាត់នឹង ត្រូវបានដកចេញពីសៀវភៅជីវិត។" ដូច្នេះ យើងនឹងមិនហ៊ានបន្ថែមអ្វីមួយទៅវា

ទេ។ អូ វាត្រូវតែនៅដដែល មិនត្រូវមានអ្វីបន្ថែមទៅវាទេ។ ហើយយើងត្រូវតែតស៊ូសម្រាប់អ្វីគ្រប់យ៉ាងដែលមាននៅក្នុងវា។ ខ្ញុំមិនចង់បានច្រើនទៀតទេ ហើយខ្ញុំក៏មិនចង់បានតិចដែរ។ ខ្ញុំចង់បានតែអ្វីដែលវានិយាយ។

22 ឥឡូវនេះ សៀវភៅហោព្រើរនេះ ហេតុផលដែលខ្ញុំបានជ្រើសរើសវាគោលបំណងមួយ រឿងមួយ សំបុត្រនេះ "បងប្រុស ប្រាណហាំជាទីគោរព!" ជាដើម។ ហើយ ខ្ញុំ—ខ្ញុំ យើងចង់នៅជាមួយព្រះបន្ទូល។

23 ឥឡូវនេះ ជំពូកទី១ គឺជាការលើកតម្កើងព្រះយេស៊ូវ ដូច្នេះទ្រង់គឺជាអង្គសំខាន់។ ហើយប៉ុលបានប្រាប់យើងនៅយប់ផ្សេងទៀតថា ទ្រង់គឺនៅក្នុងការចាប់ផ្តើមដ៏អស្ចារ្យ។ ហើយយើងបានរកឃើញថា ទ្រង់មិនមានអ្វីតូចជាងនោះទេ "ម៉ិលគីស្សាដែក ស្តេចសាឡឹម" ដ៏អស្ចារ្យនៃជំពូកទី៧។

24 ហើយឥឡូវនេះ នៅព្រឹកនេះ យើងចូលទៅជិតទ្រង់ពីមួយជំពូកទៀត—ទស្សនៈមួយទៀត ពីជំពូកទី២។ ឥឡូវនេះ បន្ទាប់ពីប៉ុលបានផ្តល់សារដ៏អស្ចារ្យនេះមកយើង អំពីការលើកតម្កើងព្រះយេស៊ូវ "ហើយថែមទាំងធ្វើឲ្យទេវតាថ្វាយបង្គំទ្រង់។" ហើយខ្ញុំគិតថា នៅទីនេះ ដូចផែនដីដែរ តើវាមានអាយុប៉ុន្មាន៖ "ហើយទ្រង់នឹងបត់វាទុកជាអាវកាក់ ប៉ុន្តែវានឹងត្រូវវិនាសទៅ តែទ្រង់នៅគង់នៅដដែល។"

25 ហើយនៅក្នុងជំពូកទី២ ឬ ខទី២ ខ្ញុំជឿថាហ្នឹងហើយ "តើថ្ងៃនេះទ្រង់មានបន្ទូលមកកាន់យើងដោយព្រះរាជបុត្រារបស់ទ្រង់ឬ។" ហើយ មើលចុះ "ឯព្រះ ដែលពីដើមទ្រង់មានព្រះបន្ទូលនឹងពួកឰយុកោដោយពួកហោរាជាច្រើនដងច្រើនបែប។" យើងបានឆ្លងកាត់ ហើយបានរកឃើញថាតើហោរាជាអ្វី និងរបៀបដែលព្រះបាននាំសាររបស់ទ្រង់មកដោយពួកហោរា។ "ប៉ុន្តែនៅថ្ងៃចុងក្រោយនេះ ទ្រង់បានមានបន្ទូលតាមរយៈព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវ ដោយព្រះវិញ្ញាណបរិសុទ្ធ។ បន្ទាប់មក ទ្រង់បាននិយាយតាមរយៈពួកហោរា។" បន្ទាប់មក យើងបានត្រឡប់មកវិញ ហើយបានដឹងថា ហោរាទាំងអស់នោះមានព្រះវិញ្ញាណនៃព្រះគ្រីស្ទនៅក្នុងពួកគេ។

26 យើងបានត្រឡប់ទៅឯយ៉ូសែបវិញ ហើយបានដឹងថាគាត់បានវាយជាតួអង្គព្រះគ្រីស្ទយ៉ាងល្អឥតខ្ចោះ។ បានត្រឡប់ទៅរកម៉ូសេវិញហើយបានឃើញថាគាត់បានក្លាយជាតួអង្គព្រះគ្រីស្ទយ៉ាងល្អឥតខ្ចោះ។ បន្ទាប់មក យើងចុះមកឯព្រះបាទដាវីឌ។ ពេលដាវីឌត្រូវគេបដិសេធនៅក្រុងយេរូសាឡឹម ដោយមិនដឹងពីមូលហេតុ

អ្វី ប៉ុន្តែបានឡើងទៅលើភ្នំ ហើយក្រឡេកមើលទៅលើភ្នំដើមអូលីវ ហើយយំចំពោះក្រុងយេរូសាឡិម ដោយព្រោះទ្រង់ត្រូវបានគេបដិសេធ។ ប្រាំបីរយឆ្នាំចាប់ពីពេលនោះមក ព្រះរាជបុត្រារបស់ព្រះបាទដាវីឌត្រូវបានបដិសេធថាជាស្តេច នៅក្រុងយេរូសាឡឹម ហើយទ្រង់គង់នៅលើភ្នំតែមួយហើយយំសោក។ អូ ព្រះវិញ្ញាណនៃព្រះគ្រីស្ទដែលទាក់ទងនឹងបុគ្គលម្នាក់ៗ!

27 ឥឡូវនេះ ប៉ុលចាប់ផ្តើម និយាយថា៖

> *ដោយហេតុនោះ បានជាគួរឲ្យយើងរាល់គ្នាប្រុងប្រយ័ត្ន លើសទៅទៀត ចំពោះសេចក្តីដែលយើងរាល់គ្នាបានឮ...*

28 ជំពូកទី២ ឥឡូវនេះ យើងកំពុងចាប់ផ្តើម។

> *ដោយហេតុនោះ បានជាគួរឲ្យយើងរាល់គ្នាប្រុងប្រយ័ត្ន លើសទៅទៀត ចំពោះសេចក្តីដែលយើងរាល់គ្នាបានឮ ក្រែង...យើងរសាត់ចេញពីសេចក្តីទាំងនោះ។*

29 អូ សូមព្រះជាម្ចាស់បើកទៅផ្ទះនោះនៅក្នុងរោងឧបោសថនៅព្រឹកនេះ។ ខ្ញុំអធិស្ឋានថាព្រះវិញ្ញាណបរិសុទ្ធនឹងជ្រាបចូលជ្រៅក្នុងចិត្តរបស់អ្នក។ "យើងគួរតែយកចិត្តទុកដាក់បំផុតចំពោះរឿងដែលយើងបានឮ។" តើយើងគួរជាមនុស្សប្រភេទណា ពេលយើងឃើញព្រះយេហូវ៉ាដ៏អស្ចារ្យចុះមកហើយធ្វើការដែលទ្រង់ធ្វើ ហើយមើលពួកគេប្រៀបធៀបបទគម្ពីរ ពីបទគម្ពីរមួយទៅបទគម្ពីរមួយ ថាពួកគេជាសេចក្តីពិតឬ? ហើយពេលខ្លះយើងអង្គុយជុំវិញដូចជាឬសនៅលើកំណាត់ឈើ ហើយគ្រាន់តែមិនខ្វល់ខ្វាយ។ យើងគួរតែរស់ រាល់នាទី ដោយព្យាយាមនាំមនុស្សទៅរកព្រះគ្រីស្ទ។ យើងគួរតែក្លាយជាថ្មដ៏រស់រវើក។ យើងមិនគួរខ្ជិលដូចយើងសព្វថ្ងៃទេ។ យើងនឹងឡើងទៅព្រះវិហារ ហើយយើងនឹងឃើញព្រះអម្ចាស់យេស៊ូវធ្វើអ្វីមួយ ឬ—ឬប្រទានពរដល់យើងតាមរបៀបនេះ ហើយបន្ទាប់មកយើងនឹង—យើងនឹងចេញទៅវិញ ហើយនិយាយថា "ការប្រជុំពិតជាល្អណាស់។"

30 ឥឡូវនេះ ការអធិប្បាយព្រះបន្ទូល យើងរីករាយនឹងវា ប៉ុន្តែនោះមិនមែនជារឿងសំខាន់នោះទេ។ នោះមិនមែនទេ។ យើងមិនគួរថ្វាយបង្គំព្រះគ្រាន់តែបន្ទាប់ពីយើងទទួលបានការអធិប្បាយពីព្រះបន្ទូល ដូចយើងជាធម្មតាធ្វើ ដោយគ្រាន់តែថ្វាយបង្គំទ្រង់។ នោះពិតជាអស្ចារ្យណាស់។ ប៉ុន្តែយើងគួរតែថ្វាយបង្គំទ្រង់ជា

រៀងរាល់ម៉ោងនៃជីវិតរបស់យើង។ ពេលយើងធ្វើការ យើងគួរតែថ្វាយបង្គំទ្រង់។ រាល់ពេលដែលឱកាសបង្ហាញខ្លួនឯង ចូរថ្វាយបង្គំព្រះអម្ចាស់ដោយថ្លែងទីបន្ទាល់អំពីទ្រង់។

បើអ្នកឃើញ អ្នករាល់គ្នាជាស្ត្រី ឃើញស្ត្រីខុសឆ្គង ចូរក្រាបថ្វាយ បង្គំព្រះអម្ចាស់ដោយយកនាងមកនិយាយថា "បងស្រី មានជីវិតប្រសើរជាងនេះ។"

31 អ្នករាល់គ្នានៅក្នុងការងាររបស់អ្នករាល់គ្នា ពេលឮគេប្រើព្រះនាមព្រះអម្ចាស់ដោយឥតប្រយោជន៍ ឆ្លៀតឱកាសទៅម្ខាងហើយចូលទៅ ហើយចាប់ដៃគាត់ ហើយនិយាយថា "អ្នកអើយ មានជីវិតប្រសើរជាងនេះ។ អ្នកមិនគួរប្រើពាក្យទាំងនេះទេ។" ហើយប្រាប់គាត់ដោយសុភាពរាបសា។ របស់ទាំងអស់នោះគឺជាការថ្វាយបង្គំ។

ហើយនៅពេលដែលយើងឃើញអ្នកជំងឺ ហើយគ្រូពេទ្យនិយាយថាមិនអាចព្យាបាលបានទៀតទេ យើងត្រូវថ្វាយបង្គំព្រះអម្ចាស់ដោយប្រាប់ពួកគេ "មានព្រះនៃស្ថានសួគ៌ដែលឆ្លើយការអធិស្ឋាន។"

32 ហើយពេលដែលយើងឃើញរឿងទាំងនោះកើតឡើង ដែលយើងឃើញថាកើតឡើងហើយសម្រេច យើងមិនគួរទុកឲ្យរឿងទាំងនេះភ្លាត់ឡើយ។ យើងគ្រាន់តែអនុញ្ញាតឱ្យវាឆ្លងកាត់ម្រាមដៃរបស់យើង។ នោះហើយជាបញ្ហាជាមួយនឹងក្រុមជំនុំពេនទីកុស្ដដ៏អស្ចារ្យនៅថ្ងៃនេះ។ ពួកគេបានបណ្ដោយឲ្យក្រែមរបស់ដំណាំរអិលតាមម្រាមដៃរបស់ពួកគេ នៅពេលពួកគេកាន់វានៅក្នុងដៃ។ ប៉ុន្តែមើលទៅអ្វីដែលពួកគេបានធ្វើ ពួកគេបានធ្វើដូចជាក្រុមជំនុំផ្សេងទៀត។ "ពួកគេបានរត់នៅក្នុងការចំណេញ -...នៅតាមផ្លូវរបស់កូរ៉ា ហើយត្រូវវិនាស ហើយផ្លូវរបស់កាអ៊ីន ហើយត្រូវវិនាសទៅក្នុងការលើកឡើងរបស់កូរ៉ា។"

33 ពួកគេបានរៀបចំ។ ជំនួសឱ្យការមានភាពជាបងប្អូនដែលយើងទាំងអស់គ្នាអាចក្លាយជាមនុស្សតែមួយ ពួកគេបានរៀបចំខ្លួនឯង។ បានបង្កើតអង្គការតូចតាចនិងស្ថាប័នតូចៗ ហើយបានផុសឡើងពីទីនោះ ហើយទើបតែបំបែកភាពជាបងប្អូន។ ហើយប្រសិនបើអ្នកមិនបានមើលទេ គឺបាទីស្ទនិងព្រេសប៊ីធើរៀននឹងរើសវាឡើងមក ពីព្រោះ "ព្រះគឺអាចយកពីថ្មទាំងនេះដើម្បីបង្កើតកូនដល់អ័ប្រាហាំ។" ហើយយើងបាន—យើងបានទុកឲ្យវារអិលចេញពីដៃដោយការបែកបាក់។

34 តើជនជាតិឥណ្ឌាបាត់បង់ប្រទេសនេះទៅបុរសស្បែកសដោយរបៀបណា? គឺដោយសារពួកគេមិនចុះសម្រុងគ្នា។ បើគេបានធ្វើជួរមុខធំមួយ...ប៉ុន្តែពួកគេឈ្លោះគ្នាទៅវិញទៅមក។ ពួកគេនឹងមានមូលដ្ឋានរបស់ពួកគេប្រសិនបើពួកគេបានជួបជុំគ្នា។

35 តើយើងនឹងបាត់បង់វាដោយរបៀបណា? ព្រោះយើងមិនចុះសម្រុងគ្នា។ របៀបដែលយើងបាត់បង់បទពិសោធន៍របស់យើងជាមួយព្រះ គឺដោយសារតែយើងមិនចុះសម្រុងគ្នា។ យើងរៀបចំមួយ ហើយហៅវាថា*នេះ*—មេតូឌីស ហើយ*នេះ*ជាបាទីស្ទ និង*នេះ*ជាអាសាមប្លី *នេះ*ជាភាពតែមួយ និង*នេះជាអ្វីផ្សេងទៀត* និងក្រុមជំនុំនៃព្រះ និងណាសារិន ភៀលគ្រីមហូលីណេស។ យើងបំបែករូបកាយរបស់ព្រះគ្រីស្ទ។ យើងមិនគួរបែកគ្នាទេ។ យើងប្រហែលជាមានគំនិតខុសគ្នា ប៉ុន្តែសូមធ្វើជាបងប្អូនក្នុងចិត្ត។ ព្រះចង់ឱ្យយើងក្លាយជាបងប្អូន។ ទ្រង់បានស្លាប់សម្រាប់ក្រុមជំនុំនៃព្រះទាំងមូល។ ហើយយើងមិនចង់ឲ្យមានការបែកបាក់គ្នាទេ។

> ឥឡូវ *ដោយហេតុនោះ បានជាគួរឲ្យយើងរាល់គ្នាប្រុងប្រយ័ត្ន*លើសទៅទៀត...ក្រែង*យើងរសាត់ចេញពីសេចក្តីទាំងនោះ។*
>
> *ដ្បិតបើសិនជាគ្រប់ទាំងព្រះបន្ទូល ដែលពួកទេវតា*បាន*ពោល*...

36 តើអ្នកឮវាទេ? "បើពាក្យដែលទេវតា..." ឥឡូវនេះ ទេវតាគឺជា "អ្នកនាំសារ។" ពាក្យថា *ទេវតា* មានន័យថា "អ្នកនាំសារ។" ហើយទើបតែបានឆ្លងកាត់ នៅក្នុងសៀវភៅទី១នៅទីនេះ "ឯព្រះ ដែលពីដើម ទ្រង់មានព្រះបន្ទូលនឹងពួកឰយុកោដោយពួកហោរា ជាច្រើនដងច្រើនបែប។" នោះគឺជាអ្នកនាំសាររបស់ព្រះ។ ហើយប្រសិនបើពួកគេជាអ្នកនាំសាររបស់ព្រះ ពួកគេគឺជាទេវតារបស់ព្រះ។ អ្នកនាំសារគឺជាទេវតា ឬ ទេវតាគឺជាអ្នកនាំសារ។

37 អ្នកនាំសារ! អ្នកគឺជាអ្នកនាំសារ ព្រឹកនេះ។ អ្នកគឺជា...អ្នកគឺជាអ្នកនាំសារនៃដំណឹងល្អ ឬអ្នកនាំសារនៃដំណឹងអាក្រក់។ អូ វាមិនស្រស់ស្អាតទេឬ បើដឹងថាយើងជាទូត យើងជាទេវតា ជាអ្នកនាំសារនៃការរស់ឡើងវិញ? ហើយយើងជាអ្នកនាំសាររបស់ព្រះដល់ពិភពបាប គឺថាព្រះគ្រីស្ទមានព្រះជន្មរស់។ នៅក្នុងចិត្ត

របស់យើង ទ្រង់មានព្រះជន្មរស់។ នៅក្នុងព្រលឹងរបស់យើង ទ្រង់មានព្រះជន្មរស់។ ហើយទ្រង់បាននាំយើងចេញពីជីវិតដ៏ថោកទាបនៃអំពើបាប ហើយលើកយើងឡើង ហើយផ្ដល់ឱ្យយើងនូវ "ហាលេលូយ៉ា" នៅក្នុងព្រលឹងរបស់យើង ហើយធ្វើឱ្យយើងក្លាយជាសុភាវៈថ្មី។ យើងជាអ្នកនាំសារ ជាទេវតានៃសេចក្ដីសញ្ញា។ អស្ចារ្យណាស់!

38 ហើយឥឡូវនេះ នៅក្នុងគម្ពីរសញ្ញាចាស់ "ប្រសិនបើ—ប្រសិនបើពាក្យដែលទេវតានិយាយនោះមានចិត្តខ្ជាប់ខ្ជួន" វិធីនោះត្រូវតែត្រឹមត្រូវ។ នៅក្នុងគម្ពីរសញ្ញាចាស់ មុនពេលដែលពាក្យរបស់ហោរាអាចបង្ហាញឱ្យឃើញ វាត្រូវតែត្រូវបានពិនិត្យនិងបញ្ជាក់។ ពួកគេមិនបានធូរលុងជាមួយវា ដូចយើងធ្វើសព្វថ្ងៃនេះទេ។

39 ចេញទៅមានអារម្មណ៍បែបណាក៏ដោយ "អូ ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ នោះហើយជាវា!" អ្នកយល់ច្រឡំហើយ។

ព្រះគម្ពីរបានចែងថា "នៅថ្ងៃចុងក្រោយ អារក្សនឹងក្លែងខ្លួនជាគ្រិស្ទាន យ៉ាងជិតស្និទ្ធ រហូតដល់វានឹងបញ្ឆោតអ្នករើសតាំងប្រសិនបើអាចធ្វើទៅបាន។" ត្រឹមត្រូវហើយ។ ដូច្នេះ យើងត្រូវតែសាកល្បង។

40 ហើយតើពួកគេបានសាកល្បងវាដោយរបៀបណាក្នុងថ្ងៃរបស់ពួកគេ? ដល់ យូរីម ធូមមីម។ បន្ទះទ្រូងរបស់អើរ៉ុន ដែលមានថ្មទាំងនោះមានដូចជា៖ បារកេត មណីជោតិ ពេជ្រ ត្បូងទទឹម ត្បូងកណ្ដៀង។ ថ្មទាំងអស់នោះ ដែលតំណាងឲ្យកំណើតនៃបុព្វបុរសទាំងដប់ពីររូបនេះ គឺនៅក្នុងបន្ទះទ្រូងរបស់អើរ៉ុន។ ហើយនៅពេលដែលហោរាម្នាក់បានទាយ ហើយពន្លឺដ៏ពិសិដ្ឋនោះបានភ្លឺមកលើវា នោះព្រះមានបន្ទូលថា "នោះគឺជាសេចក្ដីពិត។" ប៉ុន្តែ ទោះបីជាវាហាក់ដូចជាពិតយ៉ាងណាក៏ដោយ ប្រសិនបើវាមិនបានបង្ហាញពីរឿងនោះទេ វាមិនមែនជាការពិតឡើយ។ ដូច្នេះ យូរីម ធូមមីម បានទៅជាមួយបព្វជិតនោះ។

41 ប៉ុន្តែគម្ពីរនេះគឺជាយូរីមធូមមីមរបស់ព្រះសព្វថ្ងៃ។ ហើយនៅពេលដែលហោរាម្នាក់ទាយ វាច្បាស់ជាមានពន្លឺជាមួយនឹងព្រះគម្ពីរ។ បន្ទាប់មក ព្រះមានបន្ទូលថា បន្ទាប់មកទ្រង់យាងចុះមក ហើយបង្ហាញវា។

42 អូ របៀបដែលខ្ញុំអាចលើកតម្កើងព្រះនៅថ្ងៃនេះ! ខ្ញុំកំពុងគិតពីព្រឹកថ្ងៃអាទិត្យមួយទៀត អំពីរឿងនេះ នៅពេលខ្ញុំចេញពីរោងឧបោសថ។ ហើយអ្នករាល់គ្នាបាន

យំហើយសុំកុំឲ្យខ្ញុំទៅ។ ប៉ុន្តែនៅពេលដែលខ្ញុំបានអធិប្បាយអំពីដាវីឌនិងកូលីយ៉ាត និងរបៀបដែលអ្នកនឹងប្រឈមមុខនឹងពិភពលោកដ៏ត្រជាក់ និងព្រងើយកណ្តើយដែលនិយាយថាថ្ងៃនៃអព្ភូតហេតុបានកន្លងផុតទៅហើយ។

43 ខ្ញុំបាននិយាយថា "មានយក្សមួយ ហើយដរាបណាយើងអាចសម្លាប់វាបាន នោះពួកគេដទៃទៀតនឹងមានភាពក្លាហាន។" ហើយព្រះអម្ចាស់បានប្រទានដល់វា។ ហើយបន្ទាប់មកមានអូរ៉ល រ៉ូបឺតនិងជេគហ្គើរ ជាដើម ទាញដាវ ហើយយើងបានច្បាំងសត្រូវចេញពីស្រុក បិទមាត់ពួកគេ។ ពួកគេមិនអាចនិយាយថាអព្ភូតហេតុមិនកើតឡើងទេ ពីព្រោះពួកគេនៅទីនេះ។ ប្រាកដណាស់។ ព្រះបន្ទូលរបស់ព្រះគឺអស់កល្បជានិច្ច។ វាបានភ្លឺនៅលើយូរីម។ ភ្លឺនៅលើព្រះបន្ទូល នោះគឺជា យូរីមធូមមីមរបស់ទ្រង់។ ហើយនៅពេលដែលវាភ្លឺនៅលើនោះ វាជាវិជ្ជមាន។

ហើយចំពោះអ្នកណាដែលខ្វះខាត បើអ្នកជាមនុស្សមានបាប ចង់ដឹងពីរបៀបសង្គ្រោះ "ជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។"

44 ថ្ងៃនេះ យើងមានរឿងជាច្រើនដែលអ្នកត្រូវធ្វើ។ "ត្រូវបើកទំព័រថ្មី។ អ្នកត្រូវធ្វើ*បែបនេះ* ហើយធ្វើ*បែបនោះ* ដើម្បីទទួលបានការសង្គ្រោះ។"

ខ្ញុំគិតអំពីអ្នកទោសភីលីព ពេលអ្នកជាប់ឃុំសួរប៉ុលថា "តើខ្ញុំត្រូវធ្វើអ្វីដើម្បីបានសង្គ្រោះ?"

វាជាអ្នកឬខ្ញុំ យើងបានប្រាប់គាត់ពីរឿងដែលគាត់*មិនគួរ*ធ្វើ។ "អ្នកគួរតែឈប់ផឹកស្រា។ អ្នកគួរតែបោះបង់អីអីរបស់អ្នក—ការលេងល្បែងរបស់អ្នក។ អ្នកគួរតែបោះបង់*វានេះ*ចោល។ អ្នកគួរតែបោះបង់*វានោះ*ចោល។"

ប៉ុលមិនដែលប្រាប់គាត់បែបនេះទេ។ គាត់គ្រាន់តែប្រាប់គាត់ពីរឿងដែលគាត់*គួរធ្វើ*។ "ជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះអ្នកនឹងបានសង្គ្រោះ។"

45 ឥឡូវនេះ "អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿលើព្រះអង្គដែលបានចាត់ខ្ញុំមក នោះមានជីវិតអស់កល្បជានិច្ច។" នោះគឺជាពន្លឺរបស់ យូរីម ធីមមីម សាវក យ៉ូហាន៥:២៤។ "យើងជាព្រ ះអម្ចាស់ដែលប្រោសជំងឺទាំងអស់របស់អ្នក។" យ៉ាកុប ៥:១៤ "ចូរហៅអ្នកចាស់ទុំមកលាបប្រេងតាំង ហើយការអធិស្ឋាននៃសេចក្តីជំនឿនឹងជួយសង្គ្រោះអ្នកជំងឺ។" យូរីម បញ្ចេញពន្លឺ។ ឃើញទេ? នោះជាព្រះបន្ទូលដ៏អស់កល្បរបស់ព្រះ។

46 ខ្ញុំមិនខ្វល់ថាមានមនុស្សមិនគោរពកោតក្រែង មានជំនឿខុសឆ្គង មិនជឿ មានមន្ទិលសង្ស័យប៉ុន្មានទេ។ ព្រះនឹងឈរដោយព្រះបន្ទូលរបស់ទ្រង់។ ទ្រង់បានសន្យាថាទ្រង់នឹងធ្វើវា។

47 "ហើយយើងគួរតែយកចិត្តទុកដាក់បន្ថែមទៀតចំពោះរឿងទាំងនេះដែលយើងបានឮ ក្រែងមានពេលណាមួយដែលយើងបណ្តោយឱ្យវារអិល។ ដ្បិតបើពាក្យដែលទេវតា (ហោរា) បាននិយាយនោះបានខ្ជាប់ខ្ជួន..." តើពួកគេ? យើងអាចចំណាយពេលមួយសប្តាហ៍លើបញ្ហានេះទេ។

48 តើវាមានចិត្តរឹងរូសពេលម៉ូសេនិយាយឬ? វាប្រាកដណាស់។

ចុះអេលីយ៉ាឡើងលើកំពូលភ្នំវិញ? ព្រះអម្ចាស់មានព្រះបន្ទូលទៅគាត់ថា "ចូរក្រោកឡើង អេលីយ៉ា។ ខ្ញុំនឹងនៅទីនោះជាមួយអ្នក ចង់បានការប្រកបខ្លះ។" ព្រះចូលចិត្តរួមរស់ជាមួយនឹងរាស្ត្ររបស់ទ្រង់។ ប៉ុន្តែ យើងនឹងមិននៅស្ងៀមយូរល្មមឲ្យទ្រង់ប្រកបជាមួយយើងបានឡើយ។ យើងរវល់ខ្លាំងណាស់ រំលងពីកន្លែងមួយទៅកន្លែងមួយ និងច្រើនណាស់។ "ចូរនៅស្ងៀម អេលីយ៉ា។" ទ្រង់ចង់បានការប្រកបអាជីពបីឆ្នាំប្រាំមួយខែ។ យើងមិនអាចផ្តល់ពេលបីនាទីដល់ទ្រង់បានឡើយ។ បីឆ្នាំប្រាំមួយខែនៃការប្រកបថេរ។ អូ ខ្ញុំស្រលាញ់វា! បាននិយាយថា "កុំបារម្ភអំពីការចម្អិនអាហារ យើងនឹងជួសជុលវារួចហើយ។ ក្អែកនឹងចិញ្ចឹមអ្នក។ ហើយអ្វីៗនឹងទៅជាល្អ។ ខ្ញុំគ្រាន់តែចង់បានការប្រកបមួយចំនួន។" ហោរាដ៏ចំណាស់នេះឈ្មោះអេលីយ៉ា ដែលបានតាំងទីនោះនៅលើកំពូលភ្នំ ពេលដែលគាត់កំពុងប្រកបនឹងព្រះ ហេតុអ្វីបានជាប្រធានក្រុមបាននិយាយថា "ខ្ញុំជឿថាខ្ញុំនឹងឡើងទៅចាប់គាត់។" ឥឡូវនេះ អ្នកមិនដែលព្យាយាមបំបែកការប្រកបនោះទេ។

49 ដូច្នេះ មេទ័ពក៏ឡើងមកជាមួយនឹងទ័ពដ៏ធំរបស់គាត់ដែលមានចំនួនហាសិបនាក់។ ហើយគាត់បាននិយាយថា "ខ្ញុំ—ខ្ញុំ—ខ្ញុំមកយកអ្នកអេលីយ៉ា។"

50 ហើយអេលីយ៉ាក្រោកឡើង។ សូមប្រយ័ត្ន នេះជាហោរារបស់ព្រះអម្ចាស់! គាត់បាននិយាយថា "ប្រសិនបើខ្ញុំជាអ្នកបំរើរបស់ព្រ ះអម្ចាស់ សូមឲ្យភ្លើងមកពីស្ថានលើ មកលេបត្របាក់អ្នករាល់គ្នា។" ហើយភ្លើងបានធ្លាក់ចុះមក។ ប្រធានក្រុមបាននិយាយ...

51 "អូ អ្នកដឹងអ្វីទេ?" ព្រះរាជា ទ្រង់ មានបន្ទូលថា "នោះប្រហែលជា—ផ្លេកបន្ទោរ គ្រាន់តែផ្លេកបន្ទោរបានឆ្លងកាត់ ហើយវាបានវាយប្រហារពួកគេ។ ខ្ញុំនឹងបញ្ជូន ហាសិបទៀត។"

52 អេលីយ៉ាក្រោកឈរឡើង ជាទេវតាមួយអង្គ ព្រះបន្ទូលរបស់គាត់រឹងមាំ។ គាត់ ត្រូវតែជាអ្នកសងសឹកចំពោះអ្វីគ្រប់យ៉ាងដែលបានធ្វើខុស។ គាត់បាននិយាយថា "ប្រសិនបើខ្ញុំជាអ្នកបម្រើរបស់ព្រះយេហូវ៉ា សូមឲ្យភ្លើងមកចុះ។" ហើយលើកទីពីរ ហាសិបនាក់បានឆេះ។ ត្រូវហើយ។ រាល់ការតបស្នង!

*ដ្បិតបើសិនជាគ្រប់ទាំងព្រះបន្ទូល ដែលពួកទេវតាបានពោល នោះ បានឃើញថាពិតមែន ហើយគ្រប់ទាំងអំពើរំលង និងសេចក្តីរឹង* ចចេស*ក៏ត្រូវទោសចំពោះ...*

53 ឥឡូវនេះ នេះគឺជារឿងដ៏អស្ចារ្យ ខគម្ពីរបន្ទាប់។

*នោះធ្វើដូចម្តេចឲ្យយើងរួចបាន ...*

54 "នោះធ្វើដូចម្តេចឲ្យយើងរួចបាន?" ប្រសិនបើសំឡេងរបស់អេលីយ៉ានាំមកនូវ សេចក្តីវិនាស ពីព្រោះគាត់ជាទេវតារបស់ព្រះអម្ចាស់ តើយើងនឹងគេចចេញដោយ របៀបណាពេលដែលសំឡេងនៃព្រះគ្រីស្ទមានបន្ទូលមក? ឬ តើយើងអាចបរា ជ័យដោយរបៀបណាពេលអ្នកត្រូវបានអធិស្ឋាន បើវាជាសំឡេងនៃព្រះគ្រីស្ទ? ប្រសិនបើព្រះគ្រីស្ទបានតែងតាំងក្រុមជំនុំរបស់ទ្រង់ដើម្បីអធិស្ឋានសម្រាប់អ្នកឈឺ ហើយក្រុមជំនុំនឹងធ្វើតាមអ្វីដែលទ្រង់បានមានបន្ទូល ទ្រង់...ដើម្បីឱ្យពួកគេធ្វើ ដូច្នេះ តើវាអាចបរាជ័យដោយរបៀបណា? វាមិនអាចទេ។ អ្នកអាចបរាជ័យ ប៉ុន្តែ មិនអាចបរាជ័យបានទេ។ ហើយដរាបណាអ្នករក្សាវា វានឹងនាំអ្នកឆ្លងកាត់។

55 បើអ្នកបរាជ័យ អ្នកបរាជ័យដោយខ្លួនឯង។ អ្នកគ្រាន់តែចេញឆ្ងាយពី ព្រះបន្ទូល។ ប៉ុន្តែដរាបណាអ្នកនៅជាមួយព្រះបន្ទូល វាមិនអាចបរាជ័យបានទេ។ ចំពោះពាក្យរបស់ហោរាបានធ្វើ*ដូច្នេះនិងដូច្នេះ* តើព្រះបន្ទូលរបស់ព្រះគ្រីស្ទវិញនឹង មានកម្រិតណាទៀត?

*នោះធ្វើដូចម្តេចឲ្យយើងរួចបាន បើយើងធ្វេសនឹងសេចក្តីសង្គ្រោះ ដ៏ធំម្ល៉េះ ដែលព្រះអម្ចាស់បានចាប់ផ្តើមផ្សាយមក រួចពួកអ្នកដែលឮ* ក៏បាន*បញ្ជាក់មកយើងរាល់គ្នាដែរ*

56 ចូរគិតអំពីវា ដែលមានព្រះបន្ទូលដោយព្រះអម្ចាស់។ តើយើងអាចត្រឡប់ទៅបានប៉ុន្មានដង? តើយើងអាចឈប់នៅកន្លែងណា មួយម៉ោងនៅទីនេះ? នៅពេលដែលព្រះយេស៊ូវយាងមក ទ្រង់គឺដូចគ្នាកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។

57 ឥឡូវនេះ ចូរចាំថា ជាដំបូងត្រូវបានមានបន្ទូលដោយព្រះយេស៊ូវ ទ្រង់ផ្ទាល់ ហើយបន្ទាប់មកត្រូវបានបញ្ជាក់ដោយអ្នកដែលឮទ្រង់។ ឥឡូវនេះ សូមស្តាប់ទ្រង់។

58 ពេលទ្រង់យាងមកផែនដី ទ្រង់មិនបានអះអាងថាជាអ្នកព្យាបាលឡើយ។ ទ្រង់មានបន្ទូលថា "វាមិនមែនជាខ្ញុំទេដែលធ្វើកិច្ចការ។ គឺជាព្រះបិតារបស់ខ្ញុំដែលគង់នៅក្នុងខ្ញុំ។ ទ្រង់ធ្វើកិច្ចការនេះវិញ។ ព្រះរាជបុត្រាមិនអាចធ្វើអ្វីនៅក្នុងអង្គទ្រង់ឡើយ ប៉ុន្តែទ្រង់ធ្វើអ្វីដែលទ្រង់ឃើញព្រះវរបិតាធ្វើ" យ៉ូហាន ៥:១៩។

59 មើលពេលភីលីពមករកទ្រង់។ ណាថាណាអែល...បន្ទាប់ពីភីលីពបានប្រែចិត្តហើយ គាត់បានទៅរកណាថាណែល។ បាននិយាយថា "ចូរមកមើលអ្នកណាដែលយើងបានរកឃើញ៖ ព្រះយេស៊ូវជាអ្នកស្រុកណាសារ៉ែត ជាបុត្ររបស់យ៉ូសែប។"

60 ហើយគាត់បាននិយាយថា "តើអាចមានរបស់ល្អមកពីណាសារ៉ែតឬទេ?"

61 បាននិយាយថា "មកមើលសិន។" នោះជាវិធីដែលត្រូវជឿ៖ ត្រូវបញ្ជាក់។ មកហើយមើល។ អូ វាល្អបំផុតដែលខ្ញុំមិនធ្លាប់ឮ។ មកស្វែងយល់ដោយខ្លួនឯង។ កុំឈររិះគន់នៅខាងក្រៅ ប៉ុន្តែ "ចូរបញ្ជាក់គ្រប់រឿង ហើយប្រកាន់ខ្ជាប់នូវអ្វីដែលល្អ។" មកហើយមើល។

62 នៅតាមផ្លូវពួកគេបានទៅ និយាយគ្នា។ ពេលដែលគាត់ដើរឡើងក្នុងវត្តមានរបស់ព្រះអម្ចាស់យេស៊ូវ ទ្រង់មានបន្ទូលថា "មើលជនជាតិអ៊ីស្រាអែលម្នាក់ដែលគ្មានការបោកបញ្ឆោត។"

63 វាស្ទើរតែ បានយកស្បែកទាំងអស់ចេញពីគាត់។ គាត់មើលជុំវិញ និយាយថា "មែនហើយ លោកគ្រូ តើព្រះអង្គធ្លាប់ស្គាល់ទូលបង្គំនៅពេលណា? អ្នកមិនដែលឃើញខ្ញុំទេ។ តើអ្នកស្គាល់ខ្ញុំដោយរបៀបណា?" ភីលីពបាននិយាយ...

64 "ពីមុន ពេលគាត់ហៅ..." បាននិយាយថា "មុនពេលភីលីពហៅអ្នកកាលពីម្សិលមិញ ពេលអ្នកនៅក្រោមដើមឧទុម្ពរ ខ្ញុំបានឃើញអ្នក។" អាម៉ែន។

65 គាត់បាននិយាយថា "ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ។ ទ្រង់គឺជាស្តេចនៃអ៊ីស្រាអែល។"

66 ស្ត្រីម្នាក់បានដើរចូលទៅក្នុងវត្តមានរបស់ទ្រង់ ហើយទ្រង់មានបន្ទូលថា "ទៅយកប្តីរបស់អ្នក។"

នាងបាននិយាយថា "ខ្ញុំមិនមានប្តីទេ។"

67 បាននិយាយថា "ត្រូវហើយ។ អ្នកមានប្រាំនាក់ ហើយអ្នកដែលអ្នកកំពុងរស់នៅជាមួយ មិនមែនជារបស់អ្នកទេ។ អ្នកបានប្រាប់ការពិត។" គិតមើលទៅ។

68 នាងបាននិយាយថា "លោកម្ចាស់ ខ្ញុំយល់ឃើញថា លោកជាហោរា។ នោះយើងដឹងថាពេលព្រះមេស្ស៊ីយាងមក ទ្រង់នឹងប្រាប់យើងរាល់ការទាំងអស់។"

69 ទ្រង់មានបន្ទូលថា "ខ្ញុំជាទ្រង់ ដែលនិយាយទៅកាន់អ្នក។"

70 នាងរត់ទៅប្រាប់អ្នកក្រុងថា "ចូរមក មើលបុរសម្នាក់ដែលបានប្រាប់ខ្ញុំនូវអ្វីទាំងអស់ដែលខ្ញុំបានធ្វើ។ តើនេះមិនមែនជាព្រះមេស្ស៊ីទេឬ?" វាត្រូវបានមានបន្ទូលដោយព្រះអម្ចាស់។

71 តើមានអ្វីកើតឡើង? ព្រះយេស៊ូវទ្រង់មានបន្ទូលថា មុនពេលទ្រង់ចាកចេញទៅ "កិច្ចការដែលខ្ញុំធ្វើ អ្នកក៏ត្រូវធ្វើដែរ។" ត្រូវហើយ? "កិច្ចការដែលខ្ញុំធ្វើ អ្នកនឹងធ្វើលើសពីនេះទៅទៀត ដ្បិតខ្ញុំទៅឯព្រះបិតា។" អូ ខ្ញុំអាចមើលឃើញពួកគេនៅពេលពួកគេចេញទៅ គ្រប់ទីកន្លែង។ ម៉ាកុស ១៦ "ចេញទៅគ្រប់ទិសទី អធិប្បាយព្រះអម្ចាស់ធ្វើការជាមួយពួកគេ ដោយបញ្ជាក់ព្រះបន្ទូល។"

ហើយនៅទីនេះ ប៉ុល បានផ្តល់រឿងដូចគ្នា។ លោកបាននិយាយថា—ដំណឹងល្អចាប់ផ្តើមផ្សាយដោយព្រះយេស៊ូវ ហើយត្រូវបានបញ្ជាក់ដល់យើងដោយអ្នកដែលបានឮទ្រង់។ នោះជាថ្មគ្រឹះ។ សូមថ្វាយព្រះពរដល់ព្រះនាមព្រះអម្ចាស់! នោះជាថ្មគ្រឹះ។

72 ហើយបើគិតទៅ ពីរពាន់ឆ្នាំបានកន្លងផុតទៅហើយ។ អ្នកអាត្មានិយមបានកើនឡើង ហើយអ្នកមិនទៀងត្រង់ ហើយអ្នកមានមន្ទិលសង្ស័យ និងអវិជ្ជា។ ប៉ុន្តែ ថ្ងៃនេះ ព្រះយេស៊ូវដដែលនោះ បញ្ជាក់ព្រះបន្ទូលរបស់ទ្រង់តាមរបៀប

ដូចគ្នា ដោយអ្នកដែលស្តាប់ទ្រង់។ "ស្តាប់ទ្រង់" មិនមែនមានន័យថាគ្រាន់តែស្តាប់ការអធិប្បាយ។ គឺមានន័យថា ចូរស្តាប់*ទ្រង់*។ បាទ។

73 នោះធ្វើដូចម្តេចឲ្យយើងរួចបាន? តើការរត់គេចរបស់យើងនៅឯណា? អូអ្នកនិយាយថា "ប្រទានពរដល់ព្រះជាម្ចាស់ ខ្ញុំជាកម្មសិទ្ធិរបស់ក្រុមជំនុំមេតូឌីស្ទ។ ខ្ញុំជាព្រេសប៊ីធើរៀន។ ខ្ញុំជាពេនទទីកុស្ត។" វាមិនមានរឿងមួយដែលត្រូវធ្វើជាមួយវាទេ។ ហើយអ្នកទទួលបាននៅលើបន្ទាត់ចំហៀងហើយចង់ហៅវា "ខាងវិញ្ញាណ ឬវិញ្ញាណផ្លូវចិត្តមួយចំនួន ឬអារក្សខ្លះ" ឬក៏អ្វីផ្សេង។ គួរឱ្យខ្មាសគេ!

74 "ដ្បិតបើសិនជាគ្រប់ទាំងព្រះបន្ទូល ដែលពួកទេវតាបានពោល នោះបានឃើញថាពិតមែន..." ព្រះយេស៊ូវមានព្រះបន្ទូលថា "មិនមែន...បន្តិចទៀតនេះ លោកិយនឹងលែងឃើញខ្ញុំទៀតហើយ។ ទោះជាយ៉ាងណា អ្នករាល់គ្នានឹងឃើញខ្ញុំ ដ្បិតខ្ញុំនឹងនៅជាមួយអ្នក សូម្បីតែនៅក្នុងអ្នក រហូតដល់ទីបញ្ចប់នៃយុគសម័យ។" ហើយនៅពេលដែលយើងឃើញទ្រង់យាងចុះមក ដើម្បីបន្តបញ្ជាក់ព្រះបន្ទូលរបស់ទ្រង់ តើយើងនឹងគេចចេញដោយរបៀបណាបើយើងជួយក្រុមជំនុំខ្លះ ឬអង្គការមួយចំនួន ឬនិកាយ ឬទ្រឹស្តីសត្វចិញ្ចឹមតិចតួចមួយចំនួនរបស់យើងផ្ទាល់? អ្នកដោះលែងទៅល្អជាង។ "រាល់អំពើបាបបានទទួលការតបស្នងដ៏ត្រឹមត្រូវនៅក្រោមទេវតា កាន់តែច្រើនប៉ុណ្ណាពេលព្រះរាជបុត្រានៃព្រះកំពុងមានបន្ទូលពីស្ថានសួគ៌ ដើម្បីបង្ហាញព្រះបន្ទូលរបស់ទ្រង់! តើយើងនឹងគេចចេញដោយរបៀបណា បើយើងធ្វេសប្រហែសនឹងសេចក្តីសង្គ្រោះដ៏អស្ចារ្យ?" អូ ខ្ញុំអើយ! "ព្រះផងដែរ..."

ខទី ៤:

*ទាំងមានព្រះធ្វើបន្ទាល់ជាមួយផង ...*

75 មើលនេះ។ ព្រះអម្ចាស់បានធ្វើបន្ទាល់។ អូ ខ្ញុំសប្បាយចិត្តណាស់! ព្រះអម្ចាស់បានធ្វើបន្ទាល់។

76 មើល។ ពេលអេលីយ៉ាឡើងលើភ្នំ គាត់មានប្រសាសន៍ថា៖ "ប្រសិនបើខ្ញុំជាមនុស្សរបស់ព្រះ សូមឲ្យភ្លើងធ្លាក់មកពីស្ថានសួគ៌ ហើយឆាបឆេះអ្នក។" ព្រះបានធ្វើបន្ទាល់ថាគាត់*គឺជា*មនុស្សរបស់ព្រះ។

ព្រះតែងតែធ្វើជាបន្ទាល់។ ជីវិតរបស់អ្នកនឹងធ្វើជាបន្ទាល់។ ខ្ញុំមិនដឹងថាទីបន្ទាល់របស់អ្នកជាអ្វីទេ ប៉ុន្តែជីវិតរបស់អ្នកនិយាយខ្លាំងៗ សំឡេងរបស់អ្នកមិនអាចស្តាប់បានទេ។ ប៉ុន្តែ អ្នក—ការរស់នៅរបស់អ្នក ជីវិតប្រចាំថ្ងៃរបស់អ្នកនឹងថ្លែងទីបន្ទាល់ថាអ្នកជាអ្វី។ ព្រះធ្វើបន្ទាល់។ បាទ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាត្រាមួយ ហើយត្រាមួយត្រូវយកទាំងសងខាងនៃក្រដាស។ ពួកគេឃើញអ្នកឈរនៅ*ទីនេះ*ហើយឃើញអ្នកនៅពេលអ្នកទៅឆ្ងាយ។ មិនត្រឹមតែនៅក្នុងព្រះវិហារប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងការងារជារៀងរាល់ថ្ងៃ។ អ្នកត្រូវបានផ្សាភ្ជាប់ទាំងសងខាង ខាងក្នុង និងខាងក្រៅ។ ដោយក្តីអំណរដែលអ្នកមាន និងដោយជីវិតដែលអ្នករស់នៅ អ្នកត្រូវបានផ្សាភ្ជាប់ នៅក្នុងនិងខាងក្រៅ ដែលអ្នកដឹងថាអ្នកបានសង្គ្រោះ ហើយពិភពលោកដឹងថាអ្នកបានសង្គ្រោះ តាមរយៈជីវិតដែលអ្នករស់នៅ ដ្បិតព្រះជាម្ចាស់ធ្វើបន្ទាល់។ សូមថ្វាយព្រះពរដល់ព្រះនាមដ៏វិសុទ្ធរបស់ទ្រង់! ខ្ញុំអើយ ខ្ញុំមានអារម្មណ៍បែបសាសនា!

77 បងប្អូនអើយ គិតទៅ។ អូ! "ចៀមរបស់ខ្ញុំឮសំឡេងរបស់ខ្ញុំ ហើយពួកគេនឹងមិនធ្វើតាមមនុស្សចម្លែកឡើយ។" អូ របៀបដែលឈ្មោះរបស់យើងនៅលើបាតដៃរបស់ទ្រង់! គឺនៅចំពោះទ្រង់ទាំងថ្ងៃទាំងយប់។ ព្រះបន្ទូលរបស់ទ្រង់តែងតែនៅចំពោះទ្រង់ ការសន្យារបស់ទ្រង់។ ទ្រង់មិនអាចបំភ្លេចវាបានទេ។ ហើយទ្រង់ស្រឡាញ់អ្នក។

78 ឥឡូវនេះ ទ្រង់នឹងធ្វើបន្ទាល់ពីទ្រង់ផ្ទាល់។ អ្នកមិនបើកមាត់និយាយមួយម៉ាត់ទេ លោកិយនឹងដឹងថាមានអ្វីកើតឡើងចំពោះអ្នក។

> …ទាំង*មានព្រះធ្វើបន្ទាល់ជាមួយផង* ដោយ*ទីសំគាល់ ការអស្ចារ្យ និងការឫទ្ធិបារមីជាច្រើនយ៉ាង ទាំងចែកព្រះវិញ្ញាណបរិសុទ្ធមកតាមព្រះហឫទ័យទ្រង់ផង?*

79 អនុញ្ញាតឱ្យយើងយកតែបទគម្ពីរមួយឥឡូវនេះមុនពេលបិទ។ នៅថ្ងៃបុណ្យទី៥០ នៅពេលដែលពួកគេបានទទួលព្រះវិញ្ញាណបរិសុទ្ធ។ ប្រហែលបួនថ្ងៃក្រោយមក ពេត្រុសបានឆ្លងកាត់ទ្វារដែលហៅថាស្រស់ស្អាត គឺគាត់និងយ៉ូហាន។ ពួកគេថា "មើលមកយើង" ទៅបុរសម្នាក់។ ហើយគាត់បាននិយាយថា "ខ្ញុំគ្មានមាសនិងប្រាក់ទេ ប៉ុន្តែខ្ញុំនឹងឲ្យអ្នកនូវអ្វីដែលខ្ញុំមាន។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទនៃណាសារ៉ែត ចូរក្រោកឡើងហើយដើរ។" ហើយបុរសនោះ

ដើបមុខឡើង ហើយមិនបានសួរអ្វីអំពីរឿងនោះទេ។ គាត់គ្រាន់តែក្រោកឈរហើយដើរ។ ពួកគេជាមនុស្សល្ងង់និងមិនបានរៀនសូត្រ។ ប៉ុន្តែ ព្រះគម្ពីរបានចែងថា "ពួកគេត្រូវបានយកចិត្តទុកដាក់ចំពោះពួកគេ ព្រោះពួកគេដឹងថាពួកគេធ្លាប់នៅជាមួយនឹងព្រះយេស៊ូវ។"

80 បងប្រុស នៅពេលដែលពិភពលោកដឹងថាអ្នកបាននៅជាមួយព្រះយេស៊ូវ នៅពេលដែលអ្នកអាចរស់នៅក្នុងជីវិតដែលគ្មានការកែប្រែបែបនេះនៅក្នុង ពិភពលោកបច្ចុប្បន្ន និងក្នុងភាពងងឹតនេះ ដែលពិភពលោកដឹងនិងអាចមើលឃើញថាអ្នកបាននៅជាមួយព្រះយេស៊ូវ ពេលដែលស្រីពេស្យាដ៏អាក្រក់និងអាសអាភាសនៅតាមផ្លូវអាចក្លាយជាស្ត្រី លាងក្នុងឈាមរបស់កូនចៀម ព្រះកំពុងធ្វើជាសាក្សីថាទ្រង់មានព្រះជន្មរស់។

81 យកមនុស្សប្រមឹក ជាអ្នកថោកទាបដែលគាត់អាចរត់មកវាយប្រពន្ធ និងធ្វើបាបកូន ហើយយកអាហារចេញពីតុ ដើម្បីចំណាយលើស្រីពេស្យា។ សូមឲ្យគាត់ទៅជាមួយនឹងព្រះយេស៊ូវម្តង អ្នកនឹងឃើញគាត់ត្រឡប់មកវិញ ដូចជាកងពល ដែលមានគំនិតត្រឹមត្រូវនិងស្លៀកពាក់ល្អ ដល់កូនរបស់គាត់និងប្រពន្ធរបស់គាត់និងមនុស្សជាទីស្រលាញ់របស់គាត់។ ប្រាកដណាស់។

82 កាលពីមុន ប្រហែលសែសិបឆ្នាំមុន ពេលដែលសាសនានានាក្នុងលោកបានជួបគ្នា ហើយអ្នកផ្សេងក្រោកឡើងនិយាយ។ ហើយមហាម៉ាត់ដាន់បាននិយាយសម្រាប់សាសនាមហាម៉ាត់ដាន់។ ពួកចេនបាននិយាយសម្រាប់សាសនាចេន ព្រះពុទ្ធសាសនានិយាយសម្រាប់ព្រះពុទ្ធ។ ហើយពេលដែលបណ្ឌិតគួរឱ្យអាណិតម្នាក់ ខ្ញុំភ្លេចនាមត្រកូលរបស់គាត់បាត់ហើយពេលនេះ ខ្ញុំស្គាល់ឈ្មោះគាត់ ប៉ុន្តែខ្ញុំភ្លេចបាត់ហើយ គាត់និយាយដើម្បីតំណាងឲ្យគ្រីស្ទាន ហើយគាត់បានប្រាប់រឿងរបស់ឡេឌី ម៉ាកកាប៊ី នៃអូក្លាហូម៉ា នៅអាមេរិក។

នាងស្លេកស្លាំងហើយថោកទាប រហូតដល់ពេលគេទៅសម្លាប់នាង គេមិនព្រមដាក់ដៃលើនាងទេ នាងក្រីក្រនិងអាក្រក់ណាស់។ ពួកគេបានចាប់ខ្លួននាងដោយចោទប្រកាន់ថាៈ បានជក់បារី បើកបខុសល្បឿន ល្មើសនឹង—ច្បាប់—ច្បាប់ កំណត់ត្រានៅអូក្លាហូម៉ា ពេលនាងបើកតាមផ្លូវ គឺបើកមិនខ្វល់ពីអ្នកដ៏ទៃឡើយ។ ហើយនាងគឺអាក្រក់និងកខ្វក់ខ្លាំងណាស់ រហូតដល់សង្គមមិនអាចចូលទៅជិតកន្លែងដែលនាងនៅ ច្រើនណាស់រហូតដល់ពេជ្ឈឃាដនឹងប្រហារជីវិត

នាង គេមិនព្យួរកនាងឡើយ។ ពួកគេគ្រាន់តែចាក់ជ័រនិងពោមលើនាង ដើម្បីសម្លាប់នាង។

ហើយនៅពេលដែលគ្រូអធិប្បាយតូចនេះប្រាប់រឿងរបស់នាង តាមរបៀបបែបនេះ រហូតដល់ធ្វើឱ្យមនុស្សអង្គុយនៅចុងកន្លែងអង្គុយចង់ស្តាប់អ្វីនឹងកើតឡើងបន្ទាប់។ ពេលគាត់និយាយដល់ចំនុចនេះ៖ អាក្រក់ណាស់ កខ្វក់ ថោកទាប រហូតដល់ច្បាប់មិនចង់ធ្វើអ្វីឆ្កួតៗជាមួយនាងឡើយ នាងគឺថោកទាបណាស់។ អារក្សនៃនរកនឹងបដិសេធមនុស្សបែបនេះ ស្ទើរតែដូចគ្នា ជារបៀបដែលគាត់ប្រាប់រឿងនោះ។ បន្ទាប់មកគាត់បាននិយាយថា "សុភាពបុរសនៃសាសនានៃពិភពលោក តើសាសនារបស់អ្នកមានអ្វីដែលអាចសម្អាតដៃរបស់ ឡេឌីម៉ាកកាប៊ីបានទេ?"

83 គ្រប់គ្នានៅស្ងៀម។ បន្ទាប់មកគាត់បានទះដៃជាមួយគ្នា ហើយលោតឡើងលើអាកាស។ គាត់បាននិយាយថា "សូមថ្វាយសិរីល្អដល់ព្រះជាម្ចាស់! ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ មិនគ្រាន់តែសម្អាតដៃនាងប៉ុណ្ណោះទេ ប៉ុន្តែវានឹងសម្អាតចិត្តនាងហើយធ្វើឱ្យនាងក្លាយជាកូនក្រមុំរបស់ទ្រង់។" ប្រាប់អ្នកចុះ◌ះ

ព្រះគុណអស្ចារ្យ! ជាសព្ទពិរោះ
ដែលមនុស្សដូចខ្ញុំ!
ពីដើមបាត់បង់ តែទ្រង់សង្គ្រោះ
ក៏ខ្វាក់ តែទ្រង់ដឹកនាំ។

ព្រះគុណបង្រៀនឱ្យកោតខ្លាចព្រះ
ក៏បានកំចាត់ ភ័យទៅ
ព្រះគុណនោះមានតម្លៃប៉ុនណា
នៅនាទីដែលខ្ញុំបានជឿ!

84 ប្រាកដណាស់។ "តើយើងនឹងគេចយ៉ាងដូចម្តេច បើយើងធ្វេសប្រហែសបែបនេះ?" អ្នកមិនបានបរិភោគទេ អ្នកនឹងស្លាប់។ អ្នកធ្វេសប្រហែសក្នុងការបត់ អ្នកនឹងគ្រោះថ្នាក់។ អ្នកធ្វេសប្រហែសមិនឲ្យទឹកដោះគោ នាងនឹងស្ងួត។ អ្នកធ្វេសប្រហែសធ្មេញ អ្នកនឹងត្រូវដកវាចេញទាំងអស់។ ពិតប្រាកដ។ អ្នកចំណាយសម្រាប់ការធ្វេសប្រហែសរបស់អ្នក។

85 អូ រោងឧបោសថ ប្រាណហាំនិងចូលរួម ខ្ញុំសូមប្រាប់អ្នកឥឡូវនេះ។ អ្នកធ្វេសប្រហែសក្នុងការថ្លែងទីបន្ទាល់អំពីសិរីល្អរបស់ព្រះជាម្ចាស់ អ្នកមិនបានធ្វើការសរសើរតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ អ្នកនឹងឃើញថាខ្លួនអ្នកត្រជាក់ ផ្លូវឯការ និងបែរចេញ ថ្ងៃណាមួយ។ សូមអ្នកសរសើរព្រះ។ "តើយើងនឹងគេចចេញដោយរបៀបណា បើយើងធ្វេសប្រហែសនឹងសេចក្តីសង្គ្រោះដ៏អស្ចារ្យបែបនេះ?"

86 មកឃើត។ ខ្ញុំទើបតែបានកត់សម្គាល់ឃើញបងប្រុស ថម ដែលដើរខាងក្រោយនៅទីនោះ។ យើងនឹងបិទ ហើយបន្តនៅយប់នេះ បើព្រះអម្ចាស់សព្វព្រះហឫទ័យ។

ចូរយើងអធិស្ឋានមួយភ្លែត។

87 ព្រះវរបិតាស្ថានសួគ៌នៃយើង សូមប្រទានពរ និងសរសើរតម្កើង កិត្តិសព្ទសិរីរុងរឿង និងប្រាជ្ញា និងអំណាច និងចេស្តា ជារៀងរហូត។ អូ ដល់កូនចៀមនោះដែលបានតាំងនៅលើបល្ល័ង្ក ការគ្រប់គ្រង និងនគរ និងអ្វីៗទាំងអស់ត្រូវបានប្រគល់ទៅដៃរបស់ទ្រង់។ នៅពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ សម្រាប់ការរាប់ជាសុចរិតរបស់យើង ទ្រង់បានស្រែកទៅកាន់ពិភពលោក "អំណាចទាំងអស់នៅក្នុងស្ថានសួគ៌ និងផែនដីត្រូវបានប្រគល់មកក្នុងដៃរបស់ខ្ញុំ។ ដូច្នេះ ចូរទៅក្នុងពិភពលោកទាំងមូល ហើយផ្សាយដំណឹងល្អ។"

ឱកូនចៀមដែលជិតស្លាប់ ឈាមដ៏វិសេសរបស់ទ្រង់
នឹងមិនដែលបាត់អំណាចឡើយ
រហូតដល់ក្រុមជំនុំដែលសងថ្លៃលោះរបស់ព្រះ
បានសង្គ្រោះ មិនមានបាបទៀតឡើយ។

88 ជួយពួកយើង ក្នុងនាមអ្នកបម្រើ ដើម្បីមើលឃើញថា យើងកំពុងត្រូវការយ៉ាងច្រើន របៀបដែលយើងត្រូវមានក្រុមជំនុំ យើងត្រូវតែមាន*នេះ* យើងត្រូវតែមានអ្វីគ្រប់យ៉ាង។

89 ស្ត្រីរបស់យើង មុននឹងទៅព្រះវិហារ នៅតែហៅខ្លួនឯងថាជាគ្រិស្ទាន នឹងត្រូវមានសម្លៀកបំពាក់មួយប្រភេទ ឬត្រូវតែស្លៀកពាក់ឱ្យស្អាត។

ហើយគ្រូអធិប្បាយនឹងត្រូវមានលុយច្រើនមុនពេលពួកគេមក ហើយអ្វីៗត្រូវតែ*ដូច្នេះនិងដូច្នេះ*។

90 ឱព្រះគ្រីស្ទ នៅពេលដែលខ្ញុំអាននៅទីនេះ តើធ្វើដូចម្ដេច "ពួកគេដើរដោយពាក់ស្បែកចៀមនិងស្បែកពពែ រស់នៅក្នុងរណ្ដៅដី និងរូងភ្នំ ពួកគេបានវង្វេងនៅក្រោមការបៀតបៀនដ៏ឃោរឃៅ ប៉ុន្តែ បានទទួលសេចក្ដីជំនឿ" នៅក្រោមការបម្រើរបស់ទេវតា តើយើងនឹងគេចដោយរបៀបណា នៅពេលដែលព្រ ះអម្ចាស់យេស៊ូវបានប្រទានផ្ទះសម្បែង ឡាន សម្លៀកបំពាក់ និងអាហារដល់យើង ហើយយើងរអ៊ូរទាំ យើងដើរជុំវិញ យើងខ្ជិល យើងមិនដែលព្យាយាមចេញក្រៅ ហើយធ្វើអ្វីអំពីវាទេ តើយើងនឹងគេចចេញដោយរបៀបណា ព្រះជាម្ចាស់?

91 អូ ទូលបង្គំអធិស្ឋានថា ទ្រង់នឹងដុតបញ្ឆេះនូវជំនឿចាស់ ទៅក្នុងចិត្តគ្រប់ៗគ្នានៅព្រឹកនេះ ព្រះអម្ចាស់អើយ ដើម្បីឱ្យប្រជាជនអាចក្រោកឡើង។ ចូរយើងធ្វើការពេលថ្ងៃរះចុះ ព្រោះព្រះអាទិត្យលិចយ៉ាងលឿន។ ហើយអរិយធម៌កំពុងដំណើរការហើយនឹងមិនមានពេលទៀតទេ។ វានឹងបញ្ចូលគ្នាទៅក្នុងភាពអស់កល្បជានិច្ច។

92 បពិត្រព្រះអង្គអើយ សូមទ្រង់សព្វព្រះហឫទ័យឲ្យយើងរាល់គ្នាចូលទៅដោយនិមិត្ត ដោយប្រាជ្ញា ការយល់ដឹង ដើម្បីដឹងពីរបៀបចូលទៅជិតមនុស្សមានបាបហើយនាំពួកគេមកឯព្រះគ្រីស្ទ។ សូមស្ដាប់ការអធិស្ឋានរបស់អ្នកបំរើរបស់ទ្រង់ព្រះអង្គអើយ។

93 ខ្ញុំសូម ប្រសិនបើមានអ្នកណានៅទីនេះ ដែលមិនស្គាល់ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ពួកគេ តើអ្នកនឹងលើកដៃឡើងហើយនិយាយថា "ចងចាំខ្ញុំផងបងប្រុសប្រាណហាំ"? អ្នកគ្រាន់តែលើកដៃនិយាយថា "ចងចាំខ្ញុំ។ ខ្ញុំចង់ក្លាយជាគ្រីស្ទាន។ ខ្ញុំមិនចង់ធ្វេសប្រហែសទៀតទេ"? សូមព្រះប្រទានពរអ្នក អ្នកនៅខាងក្រោយនោះ នៅទីនោះ។ នរណាផ្សេងទៀត? និយាយថា "ខ្ញុំចង់លើកដៃបងប្រុសប្រាណហាំ។ ហើយខ្ញុំចង់ទទួលយកព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ខ្ញុំដែលខ្ញុំបានធ្វេសប្រហែសគ្រប់ពេលវេលា។ អូ ខ្ញុំទៅព្រះវិហារ ប្រាកដណាស់ ខ្ញុំជាកម្មសិទ្ធិរបស់ក្រុមជំនុំ។"

# ហេព្រើរ ជំពូកពីរ ១ KHM57-0825M

(Hebrews, Chapter Two [1])

## ផ្នែកសៀវភៅហេព្រើរ

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយ នៅព្រឹកថ្ងៃអាទិត្យ ថ្ងៃទី 25 សីហា 1957 នៅរោងឧបោសថប្រាណហាំ នៅ ជេហ្វឺសាន់វីល ឥណ្ឌាអាណា U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2022 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនិក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG